ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែវិច្ឆិកា ឆ្នាំ២០១៩ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៩នេះ តាមការកត់សម្គាល់ឃើញថាការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេស សម្រេចបានចំនួន ៣៣០ ៣៤៩ហ.ត ស្មើនឹង៧១,៨៨% នៃផែនការ ៤៥៩ ៥៩៤ហ.ត។ ការប្រើប្រាស់គ្រឿងយន្តសម្រាប់ការរៀបចំដីផលិតកម្មដំណាំស្រូវរដូវប្រាំងគឺស្មើនឹង៩៩,០៩% ធៀបនឹងការប្រើប្រាស់ដោយគោ-ក្របីមាន០,៩១% រីឯការចូលរួមទប់ស្កាត់បទល្មើសផ្សេងៗទៀតជាពិសេសបទល្មើសព្រៃឈើ បទល្មើសជលផលក្រោមកិច្ចសហការជាមួយគណៈកម្មការអន្តរក្រសួង ព្រមទាំងបទល្មើសចលនាសត្វដោយខុសច្បាប់ ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ចំណែកឯការចុះធ្វើអធិការកិច្ចជី-ថ្នាំកសិកម្ម ការជំរុញការងារផ្សព្វផ្សាយកសិកម្មតាមគ្រប់រូបភាពបានប្រព្រឹត្តទៅក្រោមកិច្ចសហប្រតិបត្តិការយ៉ាងល្អប្រសើរជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងសហគមន៍កសិកម្មទៅតាមភារកិច្ចក្នុងស្មារតីទទួលខុសត្រូវ។ ទន្ទឹមនឹងនេះ ព្រឹត្តិការណ៍សំខាន់ៗក្នុងខែវិច្ឆិកា ឆ្នាំ២០១៩នេះ គឺការរៀបចំកិច្ចប្រជុំសំខាន់ៗ ការទទួលជួបភ្ញៀវជាតិ-អន្តរជាតិ ការរៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេសជាច្រើន រួមទាំងការបន្តរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានាផងដែរ។

រីឯលទ្ធផល និងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗឆ្លើយតបទៅនឹងការអនុវត្តផែនការប្រចាំខែវិច្ឆិកា រួមទាំងការចូលរួមអនុវត្តកំណែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលដែលសម្រេចបានក្នុងខែវិច្ឆិកា ឆ្នាំ២០១៩នេះ មានដូចតទៅ៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ លទ្ធផលផ្នែកដាំដុះរដូវវស្សាឆ្នាំ២០១៩

#### ១.១ បញ្ចប់ផលិតកម្មដំណាំស្រូវរដូវវស្សា

ល្បឿនការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាមានលម្អិតដូចខាងក្រោម៖

- ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ២ ៨១៨ ៣២៣ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៣២ ៧៧៩ហ.ត និងដោយគ្រឿងយន្តមានចំនួន ២ ៧៨៥ ៥៤៤ហ.ត តិចជាងឆ្នាំមុនចំនួន ១៨៨ ២១៦ហ.ត
- ផ្ទៃដីសាបសម្រេចបានចំនួន ២៣ ១១៩ហ.ត តិចជាងឆ្នាំមុនចំនួន ១៣ ៨៥៤ហ.ត
- ផ្ទៃដីស្ទូង និងព្រោះសម្រេចបានចំនួន ២ ៧៣១ ៣៣៨ហ.ត ស្មើនឹង១០៥,៦១% នៃផែនការ ២ ៥៨៦ ១៥២ហ.ត តិចជាងឆ្នាំមុនចំនួន ៨ ១០៨ហ.ត។

#### ១.២ ការងារប្រមូលផលស្រូវរដូវវស្សា

ការប្រមូលផលស្រូវសម្រេចបានចំនួន ១ ៤១២ ១១៨ហ.ត ដោយទទួលបានបរិមាណផលសរុបចំនួន ៤ ៤៣៦ ២៦៥តោន តិចជាងឆ្នាំមុនចំនួន ៣៥៧ ២៦១តោន។ ទិន្នផលគិតជាមធ្យម ៣,១៤២តោន/ហ.ត។

### ២ លទ្ធផលផ្នែកដាំដុះរដូវប្រាំងឆ្នាំ២០១៩-២០២០

#### ២.១ ផលិតកម្មដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៩-២០២០

-ផ្ទៃដីភ្ជួររាស់សម្រេចបានចំនួន ៣៣៨ ៧២០ហ.ត ក្នុងនោះភ្ជួររាស់ដោយគោ-ក្របីមានចំនួន ៣ ០៦៧ហ.ត និងដោយគ្រឿងយន្តមានចំនួន ៣៣៥ ៦៥៣ហ.ត លើសឆ្នាំមុនចំនួន ៨៣ ២៥១ហ.ត

-ផ្ទៃដីសាបសម្រេចបានចំនួន ៧៣ហ.ត តិចជាងឆ្នាំមុនចំនួន ៦៧ហ.ត

អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០

-ផ្ទៃដីស្លុង និងព្រោះសម្រេចបានចំនួន ៣៣០ ៣៤៩ហ.ត ស្មើនឹង៧១,៨៤% នៃផែនការ ៤៥៩ ៥៩៤ហ.ត លើសឆ្នាំមុនចំនួន ៩៣ ៦៤៤ហ.ត

**២.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្មរដូវប្រាំងឆ្នាំ២០១៩-២០២០**

-ដំណាំរួមផ្សំអនុវត្តបានចំនួន ១២ ៩២៣ហ.ត ស្មើនឹង៣៩,៨៨% នៃផែនការ ៣២ ៤០៣ហ.ត លើសឆ្នាំមុនចំនួន ៧ ៨៤៤ហ.ត

-ដំណាំឧស្សាហកម្មអនុវត្តបានចំនួន ២១ ៧៦១ហ.ត ស្មើនឹង២០,៥៥% នៃផែនការ ១០៥ ៨៧៣ហ.ត តិចជាងឆ្នាំមុនចំនួន ៩ ១០១ហ.ត។

**២.៣ ការនាំចេញអង្ករ**

បរិមាណនាំចេញអង្ករក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ បានចំនួន ៥៦ ២០៩តោន ថយចុះចំនួន ៦ ២២៤តោន (-៩,១%) ធៀបនឹងការនាំចេញខែវិច្ឆិកា ឆ្នាំ២០១៨។ សរុបរយៈពេល១១ខែឆ្នាំ២០១៩ នាំចេញបានចំនួន ៥១៤ ១៤៩តោន ទៅកាន់ទិសដៅចំនួន ៥៦ប្រទេស ក្នុងនោះប្រទេសចិនលំដាប់ទី១ (២០៥ ៣៥៨តោន) ប្រទេសបារាំងលំដាប់ទី២ (៧០ ១៧៦តោន) ប្រទេសម៉ាឡេស៊ីលំដាប់ទី៣ (២៩ ៨៧៨តោន) ប្រទេសហុងកុងលំដាប់ទី៤ (២៤ ៥៥៤តោន) ប្រទេសអូស្ត្រាលីលំដាប់ទី៥ (១៩ ៣៤៣តោន) ប្រទេសណេដឺឡែនលំដាប់ទី៦ (១៨ ៤៣៨តោន) ប្រទេសប្រ៊ុយណេលំដាប់ទី៧ (១៦ ១២៧តោន) ប្រទេសអេស្ប៉ាញលំដាប់ទី៨ (១២ ៨៤៥តោន) ប្រទេសអង់គ្លេសលំដាប់ទី៩ (១២ ៤៨៩តោន) និងប្រទេសប៊ែលហ្ស៊ិកលំដាប់ទី១០ (១២ ៣៤៣តោន) ហើយបច្ចុប្បន្នក្រុមហ៊ុនដែលបាននាំចេញអង្ករមានចំនួន ៨៦ក្រុមហ៊ុន។

## ៣ ផ្នែកកៅស៊ូ

### ៣.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| លរ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីចម្ការកៅស៊ូសរុប (ហ.ត) | ផលិតផលអនុវត្ត ប្រចាំខែ (តោន) | បញ្ចេញលក់ ប្រចាំខែ (តោន) |
|---|---|---|---|---|---|
| I.ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៦៧០ | ៨០១ | ៣៩ | ៥០ |
| សរុប I | | **៦៧០** | ៨០១ | ៣៩ | ៥០ |
| II. ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុនសុភក្តិនិកា អ៊ីនវេសមេនគ្រុប | ១២ ៨៨៧ | ១៥ ៧៥៧ | ១ ៨១៩ | ១ ៩២៦ |
| ២ | ក្រុមហ៊ុនចម្ការកៅស៊ូតាប៉ាវ | ១ ២២៦ | ២ ៤៤៦ | ១៩៤ | ២១០ |
| ៣ | ក្រុមហ៊ុនចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៥ ៦៣១ | ៨ ៤៤០ | ៥១៥ | ៥៥១ |
| ៤ | ក្រុមហ៊ុន ស៊ីហ្វារ៉ាប់ប៊ើលីមីធីត (រតនគិរី) | ២៤១ | ២ ៧២៤ | ៦០ | |
| ៥ | ក្រុមហ៊ុនស៊ីហ្វាវីសសស់(ស្នួល) | ៣ ៨៥៩ | ៤ ៤០៦ | ៦៤១ | ៦២៤ |
| ៦ | ក្រុមហ៊ុន ឡុង ស្រេង | ៣ ៩០៨ | ៤ ១៨៦ | ៦០៥ | ៥២៥ |
| ៧ | ក្រុមហ៊ុន អាន់ម៉ារ៉ាឌីគ្រុប (ចម្ការអណ្ដូង) | ៣ ៨១៨ | ៤ ៨៣៣ | ២០១ | |
| ៨ | ក្រុមហ៊ុនអាន់ម៉ារ៉ាឌីគ្រុប (ពាមជាំង រមាសហែក) | ២ ០១០ | ៣ ៣២២ | ១៥១ | ១១៨ |
| ៩ | ក្រុមហ៊ុនក្រែក(ខេមបូឌា)ខូអិលធីឌី | ៤ ៣៥៩ | ៤ ៧៩៨ | ៦១២ | ៧៧៧ |
| សរុបII | | **៣៧ ៩៣៩** | **៥០ ៩១២** | **៤ ៧៩៨** | **៤ ៧៣០** |
| III. ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច និងចម្ការកៅស៊ូគ្រួសារ | | | | | |
| ១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៧១ ៦១០ | ២២១ ៧៣៥ | ១២ ១០០ | ១១ ៥០០ |
| ២ | ចម្ការកៅស៊ូគ្រួសារ | ១២៥ ០៦៥ | ១៦១ ១០៣ | ១៧ ៧០០ | ១៧ ៣០០ |
| សរុប III | | **១៩៦ ៦៧៥** | **៣៨២ ៨៣៨** | **២៩ ៨០០** | **២៨ ៨០០** |
| សរុប I + II + III | | **២៣៤ ៨៨៤** | **៤៣៤ ៥៥១** | **៣៤ ៦៣៧** | **៣៣ ៥៨០** |

- គួរកត់សម្គាល់ថាក្នុងខែវិច្ឆិកា ឆ្នាំ២០១៩នេះ ជ័រកៅស៊ូមានតម្លៃជាមធ្យម ១ ៣៣៣ដុល្លារ/តោន បានកើនឡើងចំនួន ២៥ដុល្លារ/តោន ស្មើនឹង១,៨៩%ធៀបនឹងខែមុន និងបានកើនឡើងចំនួន ១០៩ដុល្លារ/តោន ស្មើនឹង៩% បើធៀបរយៈពេល១១ខែ ឆ្នាំ២០១៨

- ផ្ទៃដីកៅស៊ូសរុបចំនួន ៤៣៤ ៥៥១ហ.ត ក្នុងនោះៈ ផ្ទៃដីចៀរជ័រចំនួន ២៣៤ ៨៨៤ហ.ត ស្មើនឹង៥៤%

- ផលិតផលជ័រកៅស៊ូសម្រេចបានចំនួន ៣៤ ៦៣៧តោន កើនឡើងចំនួន ៦ ៣០២តោន ស្មើនឹង២២% បើធៀបនឹងខែមុន និងបានកើនឡើងចំនួន ៧ ៨០២តោន ស្មើនឹង២៩% ធៀបរយៈពេល១១ខែ ឆ្នាំ២០១៨

- បរិមាណបញ្ចេញលក់ជ័រកៅស៊ូសម្រេចបានចំនួន ៣៣ ៥៨០តោន បានកើនឡើងចំនួន ៦ ៦៧៧តោន ស្មើនឹង ២៥% ធៀបនឹងខែមុន និងបានកើនឡើងចំនួន ៧ ៤១៦តោន ស្មើនឹង២៨% បើធៀបរយៈពេល១១ខែ ឆ្នាំ២០១៨។

### ៣.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- បានចូលរួមកិច្ចប្រជុំលើកទី១នៃគណៈកម្មាធិការបច្ចេកទេសស្តីពីការការពារដំណាំរបស់សមាគមនៃបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិនៅប្រទេសម៉ាឡេស៊ី

- ត្រួតពិនិត្យតាមដានការសារប្រមូលផលទឹកជ័រគ្រប់បណ្តាចម្ការពិសោធន៍

- ត្រួតពិនិត្យតាមដានការលាបថ្នាំរំញោច Ethephon គ្រប់បណ្តាចម្ការពិសោធន៍

- វិភាគរកស្តង់ដារសរីរសាស្ត្រទឹកជ័រ Inorganic Phosphorus (Pi) Sucrose និង Thiol (R-SH)

- វិភាគសរីរសាស្ត្រទឹកជ័រ (LD) លើចម្ការពិសោធន៍ក្លូនទ្រង់ទ្រាយធំ (LSCT) និងទ្រង់ទ្រាយតូច (SSCT)

- វិភាគសរីរសាស្ត្រទឹកជ័រ (LD) លើចម្ការពិសោធន៍សក្តានុពលទិន្នផលលើប្រព័ន្ធចង្វាក់ចៀរជ័រ d3 d4 និងប្រព័ន្ធចង្វាក់ចៀរឆ្លើល d3 d4 d5 និង d6

- ត្រួតពិនិត្យទូទៅការថែទាំ និងការពារឡូត៍ពិសោធន៍

- ស្រង់ទិន្នន័យជ័រកៅស៊ូឡូត៍ពិសោធន៍ក្លូន IRAA01 IRAA10 និង SSCT01

- រៀបចំសហការវិភាគសរីរៈទឹកជ័រ (LD) នៃឡូត៍ពិសោធន៍ក្លូន MKAA01

- ថែទាំថ្នាលបណ្តុះកូនកៅស៊ូឆ្នាំ២០១៩-២០២០

- បាញ់ថ្នាំ Dithan-M45 ការពារជំងឺ

- រៀបចំបំពង់ Root Trainer នៅថ្នាលបណ្តុះកូន

- រៀបចំឯកសារមន្ទីរពិសោធន៍ជាតិយថាប្រភេទតម្រូវតាមស្តង់ដារ ISO/IEC: 17025: 2017

- បាននិងកំពុងបន្តការពិសោធន៍ស្រាវជ្រាវលើការប្រើប្រាស់អាស៊ីត៣ប្រភេទដែលមានកំហាប់ខុសៗគ្នា។

## ៤ ផ្នែកកសិ-ឧស្សាហកម្ម

- បានចូលរួមប្រជុំក្រុមការងារបច្ចេកទេសលើវិស័យកសិកម្មកម្ពុជា-ថៃលើកទី៥

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០

- បានចូលរួមប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីគោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះចោលកាកសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម

- បានចូលរួមប្រជុំពិភាក្សាជាមួយតំណាងក្រសួងកសិកម្មជប៉ុនអំពីការត្រៀមរៀបចំកិច្ចសន្ទនាទ្វេភាគីកម្ពុជា-ជប៉ុនលើកទី៥ស្តីពីខ្សែច្រវាក់ផលិតកម្មស្បៀង

- ចុះអង្កេត និងសម្ភាសន៍ដើម្បីប្រមូលធាតុចូលសំខាន់ៗពីគ្រប់ភាគីពាក់ព័ន្ធក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សហគ្រាសធុនតូចបំផុត តូច និងមធ្យមឆ្នាំ២០១៩-២០២៥។

## ៥ ផ្នែករុក្ខាព្រៃឈើ

### ៥.១ ការងាររុក្ខាព្រៃឈើ

- បានចុះពិនិត្យផ្ទៀងផ្ទាត់គម្របព្រៃឈើឆ្នាំ២០១៨ នៅទីវាលជាក់ស្តែងចំនួន ៦៨ចំណុច ក្នុងខេត្តកំពង់ស្ពឺចំនួន ២២ចំណុច និងខេត្តពោធិ៍សាត់ចំនួន ៤៦ចំណុច និងបានទាញយករូបភាពផ្កាយរណប (Landsat8) ឆ្នាំ២០១៩ បានចំនួន ៤ផ្ទាំងសម្រាប់ការវាយតម្លៃគម្របព្រៃឈើឆ្នាំ២០២០

- បានចុះតាមដានត្រួតពិនិត្យវាយតម្លៃបច្ចេកទេសដាំដុះតាមប្រព័ន្ធកសិ-រុក្ខកម្ម និងត្រួតពិនិត្យវាយតម្លៃការអនុវត្តគម្រោងលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋក្នុងសហគមន៍ព្រៃឈើនៃសហគមន៍ព្រៃឈើគោលដៅចំនួន ៥មានៈ សហគមន៍ព្រៃឈើភ្នំធំចំណងសាមគ្គី ខ្លាខាំប៉ែន ព្រៃខ្មៅ ដំណាក់អ្នកតាថ្មពូនភូមិដំណាក់ឈ្លួល និងសហគមន៍ព្រៃឈើដំណាក់អ្នកតាថ្មពូនភូមិត្បែងពកក្នុងខេត្តកំពតដែលមានអ្នកចូលរួមសរុបចំនួន ២៤៦នាក់

- បានផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់រណារយន្តចំនួន ២គ្រឿងជូនអ្នកស្នើសុំនៅខេត្តបាត់ដំបង

- បានផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើជូនក្រុមហ៊ុនចំនួន២ដែលមានឈើហ៊ុបមូលចំនួន២០១៥ម៣ កូនឈើចំនួន៣៥ ០០០ដើម និងអុសចម្រុះចំនួន១៩ ១៦៣ស្ទែរ និងបានរៀបចំលិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើសាជាថ្មីជូនក្រុមហ៊ុន អ៊ឹង ឃ្លូ អ៊ីមផត អិចផត ឯ.ក និងក្រុមហ៊ុន ឈុន ហុង។

### ៥.២ ការងារដាំដើមឈើ

- បានថែទាំចម្ការឈើចាស់ ចម្ការពូជឈើ និងឡូតិ៍បង្ហាញកសិ-រុក្ខកម្មចំនួន ៩៨០ហ.ត នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើចំនួន ៤ទីតាំងក្នុងខេត្តកំពង់ធំ សៀមរាប ព្រះសីហនុ និងខេត្តស្វាយរៀង

- បានថែទាំចម្ការរុក្ខទិវាសរុបចំនួន ៦០ហ.ត ស្ថិតក្នុងខេត្តកំពត កណ្ដាល តាកែវ កំពង់ធំ និងខេត្តក្រចេះ

- បានថែទាំចម្ការឈើដាំមានផ្ទៃដីទំហំ ១៥២ហ.ត ឆ្នាំ២០១៩ នៅក្នុងស្ថានីយផ្សព្វផ្សាយ និងស្ដារព្រៃឈើអន្លង់ថ្ម ក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ

- បានបណ្ដុះកូនឈើចំនួន ៦កន្លែង មានចំនួន ៣ ៨០០ដើម និងប្រគេនកូនឈើដល់ព្រះសង្ឃ ចែកប្រជាពលរដ្ឋចំនួន ៣៤ ៨២៧ដើម ក្នុងនោះថ្នាលបណ្ដុះកូនឈើតាមបណ្ដាខណ្ឌរដ្ឋបាលព្រៃឈើរាជធានី-ខេត្តចំនួន ៣១ ០២៧ដើម

- បានអនុវត្តឡូតិ៍បង្ហាញកសិ-រុក្ខកម្មនៅសហគមន៍ចំបក់ហោះនៅស្រុករវៀង ខេត្តព្រះវិហារ និងថែទាំឡូតិ៍បង្ហាញកសិ-រុក្ខកម្មទំហំ ១២ហ.ត មានដំណាំកសិកម្ម៖ កូនស្វាយចន្ទីចំនួន ២ ៥០០ដើម ចេកចំនួន ១ ៣៥០ដើម និងកូនគ្រញូងបេង និងធ្នង់សរុបចំនួន ២ ៧០០ដើម។

### ៥.៣ ការងារអភិរក្សសត្វព្រៃ

- បានចុះសិក្សាស្រាវជ្រាវ និងតាមដានវត្តមានសត្វព្រៃចំនួន ១លើក នៅតំបន់សហគមន៍នេសាទបឹងស្នេហ៍ក្នុងឃុំបាយ ស្រុកបាភ្នំ ខេត្តព្រៃវែង ដោយបានកត់ត្រាប្រភេទសត្វបក្សីចំនួន ៥០ប្រភេទ និងឧរង្គសត្វចំនួន ១១ប្រភេទ និងបានសហការជាមួយអង្គការ FFI ចុះពិនិត្យម៉ាស៊ីនថតស្វ័យប្រវត្តិចំនួន ៧គ្រឿង ដែលបំពាក់សម្រាប់តាមដានវត្តមានសត្វដំរី និងប្រភេទសត្វព្រៃផ្សេងទៀតនៅតំបន់ជួរភ្នំក្រវាញក្នុងភូមិសាស្ត្រថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង

- ផ្ដល់លិខិតអនុញ្ញាតថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសារចំនួន ២ច្បាប់ នៅខេត្តកោះកុង និងខេត្តរតនគិរី។

### ៥.៤ បង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

- កសិដ្ឋានចំនួន ៦កន្លែង បានថែរក្សា និងបង្កាត់ពូជស្វាក្ដាមសរុបចំនួន ៥១ ៨១០ក្បាល ក្នុងនោះកូនកើតក្នុងខែចំនួន ១ ៣៨៨ក្បាល

- បានធ្វើការនាំចេញសត្វស្វាក្ដាមទៅក្រៅប្រទេសចំនួន ២ ១៦០ក្បាល

- នៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមានសត្វព្រៃសរុបចំនួន ១ ៤៤៨ ក្បាល(បក្សីចំនួន ៥៣ប្រភេទ ថនិកសត្វចំនួន ៤១ប្រភេទ និងល្មូនចំនួន ១៣ប្រភេទ) សង្គ្រោះសត្វថ្មីចំនួន ១១៧ក្បាល ព្យាបាលសត្វព្រៃរបួសឈឺចំនួន ២០ក្បាល ស្ដារលទ្ធភាពជីវសាស្ត្រសត្វព្រៃ និងដោះលែងសត្វព្រៃគ្រប់ប្រភេទទៅព្រៃធម្មជាតិចំនួន ២៧២ក្បាល

- គម្រោងអភិរក្សក្រពើកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FFI បានល្បាតនៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន ៥គឺ អារ៉ែង ឆាយរាប តំបន់ស្ដារក្រពើស្ទឹងដាច់ ស្ទឹងខៀវ (ខេត្តកោះកុង) និងអូរសោម (ខេត្តពោធិ៍សាត់)

- បានបណ្ដុះបណ្ដាលប្រជាសហគមន៍នៅភូមិពោធិ៍បឹង ឃុំជងពែង ស្រុកស្រែអំបិល ខេត្តកោះកុង ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់នូវបច្ចេកទេសចិញ្ចឹមមាន់ និងដំណាំស្រូវបានចំនួន ២១៥នាក់។

- បានជួសជុលផ្លូវក្រាលក្រួសក្រហមចំនួន ៦៥៥ម៉ែត្រការ៉េ និងកាប់ឆ្ការអនាម័យព្រៃបានទំហំ ៧,២៩ហ.ត នៅក្នុងតំបន់សួនសត្វ។

### ៥.៥ ការងារនីតិកម្មនិងវិវាទ

- សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងកាប់រានដីព្រៃសរុបចំនួន ១៥៦ករណី ដោយពិន័យអន្តរការណ៍ចំនួន ៧៥ករណី និងបញ្ជូនទៅតុលាការចំនួន ៨១ករណី

- ចំពោះវត្ថុតាងនៃបទល្មើសព្រៃឈើដែលបានចាប់ឃាត់ និងដកហូតរួមមានឈើមូល-ជ្រុងសរុបចំនួន ៣៥ម៣ ឈើអារសរុបចំនួន ២៦៩ម៣ សត្វព្រៃចម្រុះប្រភេទសរុបចំនួន ៣៩៦ក្បាល និង ១៦៦គ.ក្រ ផ្ទៃដីព្រៃដែលបានកាប់រានទំហំ ៥៣ហ.ត (ចំនួន ៦ករណី) និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗទៀត។

### ៥.៦ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- បានពិនិត្យ និងពន្យារសុពលភាពរោងម៉ាស៊ីនអារកែច្នៃឈើចំនួន១ក្រុមហ៊ុន

- បាននាំចេញផលិតផលអនទេរតាទៅក្រៅប្រទេសដោយក្រុមហ៊ុនចំនួន៣មានបរិមាណចំនួន៧ម៣ និងជ័រទឹកចំនួន ៨៣តោន

- បានផ្តល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញជូនក្រុមហ៊ុនចំនួន៣មានបរិមាណផលិតផលឈើកែច្នៃ (ក្តារកាវ៉ូក្រាល កែច្នៃពីឈើនាំចូល) ចំនួន៧៥ម៣ និងជ័រទឹកចំនួន៨៦តោន។

### ៥.៧ ការងារចំណូលព្រៃឈើ

- ចំណូលពីថ្លៃសួយសារព្រៃឈើសរុបចំនួន ១ ៣៨៤ ៧៦៤ ៨៧០រៀល និង ៦ ៥៦៩,១៩ដុល្លារ។

## ៦ ផ្នែកផលិតកម្ម និងបសុព្យាបាល

**៦.១ ការងារផលិតកម្ម៖** បាននិងកំពុងពង្រឹងការងារផលិតកម្មសត្វតាមរយៈការបណ្តុះបណ្តាលគ្រូបង្គោលលើជំនាញបច្ចេកទេសចិញ្ចឹមសត្វ ចុះតាមដានស្ថានភាពចិញ្ចឹមសត្វ ណែនាំបច្ចេកទេសចិញ្ចឹមដល់កសិករចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតាមបណ្តាខេត្ត និងបន្តរៀបចំកែសម្រួលឯកសារបច្ចេកទេសចិញ្ចឹមគោ ជ្រូក មាន់ជាលក្ខណៈគ្រួសារ ព្រមទាំងតាមដានស្ថានភាពតម្លៃសត្វពីបណ្តារាជធានី-ខេត្តរៀងរាល់សប្តាហ៍។ ក្រៅពីនេះ អង្គភាពជំនាញកំពុងបន្តអនុវត្ត៖ (ក) ការងារកែលម្អពូជតាមរយៈការចុះអប់រំផ្សព្វផ្សាយពីការជ្រើសរើសពូជសត្វប្រកបដោយគុណភាព (ខ) ការលើកកម្ពស់ការយល់ដឹងខ្ពស់លើការប្រើប្រាស់ចំណីសត្វ និងចំណីផ្សំស្រេចប្រកបដោយគុណភាព និងសុវត្ថិភាព ព្រមទាំងបន្តផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការដាំដំណាំចំណីសត្វ ការធ្វើសូនដំណាំចំណីសត្វ ការផ្តល់ពូជស្មៅដល់កសិករ និងភ្នាក់ងារសុខភាពសត្វភូមិ។

### ៦.២ ការងារបសុព្យាបាល

• **លទ្ធផលត្រួតពិនិត្យ បង្ក្រាបបទល្មើសសត្វ និងផលិតផលមានដើមកំណើតពីសត្វ៖** ក្នុងខែវិច្ឆិកា ឆ្នាំ២០១៩នេះ រាជធានី-ខេត្តចំនួន១១ បាននិងកំពុងអនុវត្តជីវសុវត្ថិភាពដោយបានបាញ់ថ្នាំរំងាប់មេរោគចំនួន ៣៩ ៥៣៦លើក នៅតាមកសិដ្ឋានចិញ្ចឹមសត្វ ទីកន្លែងចិញ្ចឹមសត្វ សត្តឃាតដ្ឋាន ទីកន្លែងលក់បក្សី និងកន្លែងផ្ទះជំងឺសត្វ។ បទល្មើសសត្វនិងផលិតផលមានដើមកំណើតពីសត្វត្រូវបានត្រួតពិនិត្យ និងបង្ក្រាបយ៉ាងសកម្មដោយក្រុមអន្តរាគមន៍របស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តសរុបចំនួន ២៧ករណី ក្នុងនោះឃាត់ចាប់ចំនួន ៨ករណី និងត្រួតពិនិត្យមានលិខិតអនុញ្ញាតត្រឹមត្រូវចំនួន ១៩ករណី។

• **ការងារសុខភាពសាធារណៈ៖** ចុះវាយតម្លៃការស្នើសុំបន្តសុពលភាពសត្តឃាតដ្ឋានជ្រូកប្រភេទ "ខ" ចំនួន ២កន្លែង នៅខេត្តកណ្តាល។

• **ការងារផ្សព្វផ្សាយបច្ចេកទេស៖** ចុះបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វ និងដាំដំណាំចំណីសត្វនៅតាមខេត្តចំនួន៣។

• **ការងារនីតិកម្មនិងវិវាទ៖** សេចក្តីព្រាងប្រកាសស្តីពីនីតិវិធីនៃការផ្តល់លិខិតអនុញ្ញាត និងកំណត់ការគ្រប់គ្រងចំណី វត្ថុធាតុដើម ឬសារធាតុបន្ថែមដែលធ្វើពាណិជ្ជកម្ម ការផលិត និងធ្វើការលាយផ្សំ។

### ៦.៣ ការងារស្រាវជ្រាវ

• **ការងារស្រាវជ្រាវផលិតកម្ម៖** បច្ចុប្បន្ននេះនៅស្ថានីយពិសោធន៍ពូជគោភ្នំតាម៉ៅមានគោសរុបចំនួន ៩៦ក្បាល ក្នុងនោះគោប្រាម៉ាន់កាត់ ២៤ក្បាល គោបៅដោះ ៣៥ក្បាល គោកំផែងសែន ៣៧ក្បាល។ ដោយឡែក នៅស្ថានីយពិសោធន៍ពូជជ្រូកកម្ពុជា-ចិនមានជ្រូកសរុប ១៥១ក្បាល។

• **ការងារស្រាវជ្រាវបសុព្យាបាល៖** ក្នុងគោលបំណងត្រួតពិនិត្យ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺឆ្លងសត្វបានទាន់ពេលវេលា អង្គភាពជំនាញតែងតែយកចិត្តទុកដាក់តាមដានស្រាវជ្រាវជំងឺសត្វតាមរយៈការចុះអង្កេតតាមដាននិងយកវត្ថុវិភាគនៅតាមកន្លែងដែលមានសត្វឈឺ និងងាប់ ឬនៅតាមសត្តឃាតដ្ឋានសរុបចំនួន ៩៧១វត្ថុវិភាគ ដើម្បីធ្វើការវិភាគរកប្រភេទមេរោគបង្កជំងឺ ជាពិសេសមេរោគជំងឺផ្តាសាយបក្សី និងជំងឺប៉េស្តជ្រូកអាហ្វ្រិក (ASF)។

## ៧ ផ្នែកជលផល

### ៧.១ អាជីវកម្មនេសាទ

៧.១.១ នេសាទទឹកសាប

- ជាយត្រីអនុវត្តចំនួន ១ ៣៨០តោន សរុបរយៈពេល១១ខែបានចំនួន ៣ ៩២០តោន ស្មើនឹង៣២,៦៧% នៃផែនការ ១២ ០០០តោន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ ថយចុះចំនួន ១ ២៥០តោន

- នេសាទគ្រួសារក្នុងដែននេសាទអនុវត្តចំនួន ៤៤ ៥០០តោន សរុបរយៈពេល១១ខែបានចំនួន ២៧២ ១០០តោន ស្មើនឹង៧៨,៨៧% នៃផែនការ ៣៤៥ ០០០តោន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ ថយចុះចំនួន ២៣ ៤៣០តោន

- នេសាទគ្រួសារតាមវាលស្រែអនុវត្តបានចំនួន ២៤ ១០០តោន សរុបរយៈពេល១១ខែបានចំនួន ១០៨ ៩៣០តោន ស្មើនឹង៧៥,១២% នៃផែនការ ១៤៥ ០០០តោន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ ថយចុះចំនួន ១៦ ៨០០តោន។

៧.១.២ នេសាទសមុទ្រ

អនុវត្តបានចំនួន ១១ ៩៥០តោន សរុបរយៈពេល១១ខែបានចំនួន ១១១ ២៥០តោន ស្មើនឹង១០១,១៤% នៃផែនការ ១១០ ០០០តោន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ កើនឡើងចំនួន ៤០០តោន។

### ៧.២ វារីវប្បកម្ម

- ការចិញ្ចឹមត្រីនិងបង្គាអនុវត្តបានចំនួន ២២ ២០០តោន សរុបរយៈពេល១១ខែបានចំនួន ២៩៧ ៨០៨តោន ស្មើនឹង៩៩,២៧% នៃផែនការ ៣០០ ០០០តោន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ កើនឡើងចំនួន ៥២ ៤៥៨តោន

- ការចិញ្ចឹមក្រពើអនុវត្តបានចំនួន ២៥ ០០០ក្បាល សរុបរយៈពេល១១ខែបានចំនួន ៣០៧ ៩០០ក្បាល ស្មើនឹង ១០២,៦៣% នៃផែនការ ៣០០ ០០០ក្បាល ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ ថយចុះចំនួន ៧ ០០០ក្បាល

- ការភ្ញាស់កូនត្រីពូជអនុវត្តបានចំនួន ២៥ ៩០០ ០០០កូន សរុបរយៈពេល១១ខែបានចំនួន ២០៨ ០០០ ០០០កូន ស្មើនឹង៨៦,៦៧% នៃផែនការ ២៤០ ០០០ ០០០កូន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ កើនឡើងចំនួនប្រមាណ ១១ ០០០ ០០០កូន។

### ៧.៣ ការកែច្នៃផលនេសាទ

- ផលនេសាទទឹកសាបក្នុងរដូវនេសាទអនុវត្តចំនួន ៤ ៧០០តោន សរុបរយៈពេល១១ខែបានចំនួន ៥០ ៦០០តោន ស្មើនឹង៦១,៧១% នៃផែនការ៨២ ០០០តោន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ ថយចុះចំនួន ១៥ ៤០០តោន

- ផលនេសាទសមុទ្រអនុវត្តបានចំនួន ១ ១០០តោន សរុបរយៈពេល១១ខែបានចំនួន ១០ ៦៤០តោន ស្មើនឹង ១១៨,២២% នៃផែនការ ៩ ០០០តោន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ កើនឡើងចំនួន ៣២៥តោន

- ការផលិតទឹកត្រីអនុវត្តបានចំនួន ៣ ៦០០ ០០០លីត្រ សរុបរយៈពេល១១ខែបានចំនួន ៥៤ ០០០ ០០០លីត្រ ស្មើនឹង៩៨,១៨% នៃផែនការ៥៥ ០០០ ០០០លីត្រ ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ ថយចុះចំនួន ១ ០០០ ០០០លីត្រ។

### ៧.៤ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផល

- សំណុំរឿងបទល្មើសជលផលមានចំនួន ២៦៦ករណី ប្រៀបធៀបក្នុងឆ្នាំ២០១៨ ថយចុះចំនួន ៣៣ករណី ក្នុងនោះបទល្មើសទឹកសាបចំនួន ២៤៩ករណី និងសមុទ្រចំនួន ១៧ករណី។

### ៧.៥ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់អនុវត្តបានចំនួន ៦០០តោន សរុបរយៈពេល១១ខែបានចំនួន ៨ ៧០០តោន ស្មើនឹង៥៨% នៃផែនការ ១៥ ០០០តោន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ ថយចុះចំនួន ៨០០តោន

- ផលនេសាទកែច្នៃអនុវត្តបានចំនួន ៣០០តោន សរុបរយៈពេល១១ខែបានចំនួន ៤ ៦៨០តោន ស្មើនឹង៩៣,៦០% នៃផែនការ ៥ ០០០តោន ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ ថយចុះចំនួន ៣២០តោន។

### ៧.៦ ការប្រមូលថវិកា

ចំណូលពីសេវាផ្សេងៗក្នុងផ្នែកជលផលក្នុងខែវិច្ឆិកា ឆ្នាំ២០១៩ ចំនួន ៥ ៣២០ ០០០រៀល សរុបរយៈពេល ១១ខែបានចំនួន ៤៦៧ ៩៨៦ ១៩៨រៀល ស្មើនឹង១៥,៣៨% នៃផែនការ ៣ ០៤៣ ០០០ ០០០រៀល ប្រៀបធៀបរយៈពេល១១ខែ ឆ្នាំ២០១៨ ថយចុះចំនួន ១ ០៥៩ ៥៦៦ ៧៦០រៀល។

## ៨ ផ្នែកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការពិនិត្យឡើងវិញលើការវិនិយោគវិស័យកសិកម្មនៅកម្ពុជា
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំផែនការមេអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០៣០
- បានចុះពិនិត្យការងារនៅស្ថានីយស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកោះកេរ្តិ៍នៅខេត្តព្រះវិហារ
- បានចុះប្រមូលគ្រាប់ពូជដំណាំបន្លែនៅខេត្តក្រចេះ
- បានចុះប្រមូលទិន្នន័យពិសោធន៍នៅខេត្តកំពង់ស្ពឺ និងខេត្តត្បូងឃ្មុំ
- បានចុះត្រួតពិនិត្យ ពិសោធ និងវាយតម្លៃដីនៅខេត្តមណ្ឌលគិរី រតនគិរី និងខេត្តស្ទឹងត្រែង
- បានចុះត្រួតពិនិត្យសកម្មភាពពិសោធន៍ និងស្ថានភាពគ្រប់គ្រងទ្រព្យសម្បត្តិវិទ្យាស្ថាន(រដ្ឋ)នៅខេត្តព្រះវិហារ

- បានចុះរៀបចំទិវាស្រែបង្ហាញនៅខេត្តឧត្តរមានជ័យ។

## ៩ ផ្នែកនីតិកម្មកសិកម្ម

### ៩.១ ការងារអាជីវកម្មសម្ភារកសិកម្ម

- ចេញលិខិតអនុញ្ញាតនាំចូលថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៥ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្រចុះបញ្ជិកាថ្នាំកសិកម្ម និងជីកសិកម្មចំនួន ១៥ក្រុមហ៊ុន
- ចេញវិញ្ញាបនបត្រចុះបញ្ជីឃ្លាំងសន្និធិថ្នាំកសិកម្ម និងជីកសិកម្មចំនួន ៦ក្រុមហ៊ុន
- ចេញលិខិតអនុញ្ញាតផ្គត់ផ្គង់ចែកចាយថ្នាំកសិកម្ម និងជីកសិកម្មបានចំនួន ៣ក្រុមហ៊ុន។

### ៩.២ ការងារមន្ទីរពិសោធន៍

ធ្វើវិភាគរកសារធាតុបន្ទាប់បន្សំ និងលោហៈធ្ងន់នៅក្នុងសមាសភាពផ្សំនៃជីកសិកម្មដែលស្នើសុំវិភាគចំនួន ៩ក្រុមហ៊ុន សរុបចំនួន ៤៧សំណាក។

### ៩.៣ ការងារបណ្តុះបណ្តាល អប់រំ និងលើកកម្ពស់ការយល់ដឹង

- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងស្តីពីបទដ្ឋានគតិយុត្ត នីតិវិធី និងវិធានបច្ចេកទេសក្នុងការគ្រប់គ្រង និងការធ្វើអាជីវកម្មសម្ភារកសិកម្មដែលមានអ្នកចូលរួមចំនួន ៥៤នាក់។

## ១០ ផ្នែករដ្ឋបាល

- ក្នុងខែវិច្ឆិកា ឆ្នាំ២០១៩នេះ បានទទួលលិខិតសរុបចំនួន ៨៥៣ច្បាប់ ក្នុងនោះពីក្រសួង-ស្ថាប័ននានាចំនួន ៣១៩ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទចំនួន ៣៦៤ច្បាប់ ទទួលពីរាជធានី-ខេត្តចំនួន ១៧០ច្បាប់ និងបានចាត់ចែងរៀបចំលិខិតឆ្លើយតបបន្តតាមចរន្តការងាររដ្ឋបាល

- បានបញ្ជូនឯកសារនិងលិខិតទៅក្រសួង-ស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី-ខេត្តចំនួន ១ ១៨១ច្បាប់ ចេញប្រកាស សេចក្តីសម្រេច និងសារាចរណែនាំចំនួន ៤២ច្បាប់ និងចម្លងផ្សព្វផ្សាយចែកទៅអង្គភាពក្រោមឱវាទបានចំនួន ១៣ច្បាប់

- បានបូកសរុបរបាយការណ៍របស់ក្រសួងប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ

- ថ្នាក់ដឹកនាំនាយកដ្ឋានកិច្ចការរដ្ឋបាលបានសម្របសម្រួលចាត់ចែងក្នុងពិធីផ្សេងៗ និងបានចូលរួមរាល់កិច្ចប្រជុំដើម្បីក្តាប់ឱ្យបានរាល់ការងារពាក់ព័ន្ធរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សម្របសម្រួលក្នុងការរៀបចំចាត់ចែងកិច្ចការរដ្ឋបាលទូទៅ ពិធីការក្នុងការទទួលគណៈប្រតិភូជាតិ-អន្តរជាតិ ការរៀបចំកិច្ចប្រជុំនិងពិធីបុណ្យផ្សេងៗ ការងារសន្តិសុខសណ្តាប់ធ្នាប់រួមរបស់ក្រសួងបានល្អ ព្រមទាំងចាត់ចែងលិខិតអញ្ជើញផ្សេងៗតាម Telegram ផ្សព្វផ្សាយព័ត៌មានផ្សេងៗ តាមរយៈគេហទំព័រ៖ www.maff.gov.kh, Facebook MAFF: ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ១១ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសចំនួន ៦ ៥៩៥នាក់ (ស្រី១ ៥៧០នាក់) ស្មើនឹង២៣,៨០% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន ២ ៨៤៧នាក់ (ស្រី៨១៣នាក់) ស្មើនឹង២៨,៥៤%
  + អង្គភាពថ្នាក់រាជធានី-ខេត្តចំនួន ៣ ៧៤៨នាក់ (ស្រី៧៥៧នាក់) ស្មើនឹង២០,១៩%

- បន្តការបញ្ចូលទិន្នន័យមន្ត្រីរាជការតាមអង្គភាពក្រោមឱវាទក្រសួងទៅក្នុងប្រព័ន្ធគ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា (HRMIS) សរុបបានចំនួន៨៤% នៃចំនួនមន្ត្រីរាជការសរុប

- បានចេញប្រកាសផ្ទេរមន្ត្រីរាជការចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន២នាក់

- បានចេញប្រកាសលុបឈ្មោះមន្ត្រីរាជការចេញពីក្របខ័ណ្ឌសរុបចំនួន៤នាក់ ក្នុងនោះ៖ មរណភាពចំនួន១នាក់ បោះបង់ចោលការងារចំនួន២នាក់ និងលាឈប់ពីការងារចំនួន១នាក់

- បានចេញលិខិតអនុញ្ញាតច្បាប់ឈប់សម្រាកសរុបចំនួន១០នាក់ (ស្រី៣នាក់) ក្នុងនោះ៖ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំចំនួន៩នាក់ និងច្បាប់សម្រាកមាតុភាពមានចំនួន១នាក់

- ការងារបណ្តុះបណ្តាលក្នុង និងក្រៅប្រទេសសរុបចំនួន ៣៥៤នាក់ (ស្រី៥០នាក់) ក្នុងនោះ៖
  + ការបណ្តុះបណ្តាលក្នុងប្រទេសរយៈពេលខ្លី និងមធ្យមសរុបចំនួន ១០១នាក់ (ស្រី២០នាក់)

+ ការបណ្តុះបណ្តាលក្រៅប្រទេសសរុបចំនួន ២៥៣នាក់(ស្រី៣០នាក់)។

## ១២ ផ្នែកមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម

- បន្តសកម្មភាពការងារលើការតាមដាន និងតំហែទាំគេហទំព័ររបស់ក្រសួង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តឲ្យដំណើរការរលូនជាប្រចាំ

- ធ្វើបច្ចុប្បន្នភាពបន្ថែមនៅលើគេហទំព័រនៃអង្គភាពធំៗទាំង៥ គឺ៖ រដ្ឋបាលជលផល រដ្ឋបាលព្រៃឈើ អគ្គនាយកដ្ឋានកសិកម្ម អគ្គនាយកដ្ឋានកៅស៊ូ និងអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ

- សកម្មភាពការងារក្នុងប្រព័ន្ធព័ត៌មានភូមិសាស្ត្រកសិកម្ម បានរៀបចំសម្អាតទិន្នន័យ បញ្ចូលទិន្នន័យដំណាំរួមផ្សំដំណាំកសិ-ឧស្សាហកម្មនៅខេត្តកោះកុង និងខេត្តកំពង់ស្ពឺ។ ចុះបណ្តុះបណ្តាលការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រកសិកម្ម និងប្រមូលចងក្រងទិន្នន័យគ្រោះមហន្តរាយ ដល់មន្ត្រីនៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តចំនួន៣៖ រាជធានីភ្នំពេញ កំពង់ស្ពឺ និងខេត្តកោះកុង

- រៀបចំសិក្ខាសាលាស្តីពីវឌ្ឍនភាពនៃការប្រើប្រាស់គេហទំព័ររបស់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបច្ចេកវិទ្យាព័ត៌មានក្នុងវិស័យកសិកម្មនៅខេត្តសៀមរាបមានអ្នកចូលរួម សរុបចំនួន៥៦នាក់។

## ១៣ ការងារអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១៣.១ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំសិក្សា២០១៨-២០១៩ សរុបចំនួន ៣ ០៥២នាក់ ចែកចេញជា ១០មហាវិទ្យាល័យគឺ៖ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាបត្ររង និងថ្នាក់បរិញ្ញាបត្រវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមសម្រាប់ការបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានដំណើរការវគ្គបណ្តុះបណ្តាលដោយជោគជ័យ ស្តីពីបច្ចេកទេសកែច្នៃនិងវេចខ្ចប់ផលិតផលកសិកម្ម

- បានរៀបចំសិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងឧត្តមសិក្សាកសិកម្ម ជូនថ្នាក់ដឹកនាំនិងមន្ត្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មទាំងមូល ដោយមានកិច្ចសហការជាមួយធនាគារពិភពលោកក្នុងគម្រោងពង្រឹងគុណភាពឧត្តមសិក្សា របស់នាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និងកីឡា

- បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកវិទ្យាជីវឧស្ម័នជូនដល់សមាជិក សមាជិកា នៃមជ្ឈមណ្ឌលបច្ចេកវិទ្យានិងព័ត៌មានជីវឧស្ម័នខ្នាតធំ ជាពិសេសការស្រាវជ្រាវកែឆ្នៃម៉ាស៊ីនប្រើប្រាស់សាំងឱ្យទៅជាម៉ាស៊ីនប្រើប្រាស់ឧស្ម័ន ចេញពីឡជីវឧស្ម័នវិញ

- បានចុះអនុស្សរណៈនៃការយោគយល់ជាមួយសាកលវិទ្យាល័យ Kansas State University ស្តីពីកិច្ចសហការលើការបណ្តុះបណ្តាលនិងផ្តល់មូលនិធិស្រាវជ្រាវសម្រាប់បង្កើតផលិតផលនិងសេវាកម្មថ្មីបម្រើវិស័យឯកជន

- បានលើកគម្រោងសំណើស្រាវជ្រាវចំនួន ៨ដើម្បីដាក់ជូនគណៈកម្មការត្រួតពិនិត្យគម្រោងស្រាវជ្រាវរបស់គម្រោងពង្រឹងគុណភាពឧត្តមសិក្សា (HEIP)។

### ១៣.២ សាលាជាតិកសិកម្មព្រែកលៀប

- និស្សិតដែលកំពុងសិក្សាសម្រាប់ឆ្នាំសិក្សា២០១៨-២០១៩ សរុបចំនួន ៥៣០នាក់ (ស្រី២៧២នាក់) លើជំនាញ៖ កសិកម្ម ជលផល ព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ សាកវប្បកម្ម ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សេដ្ឋកិច្ច និងគ្រប់គ្រងកសិកម្ម កសិ-ឧស្សាហកម្ម និងសុរិយោដី

- បានទៅធ្វើទស្សនកិច្ចនៅកសិដ្ឋានចិញ្ចឹមគោយកទឹកដោះនៅប្រទេសវៀតណាម

- សិក្សាពិសោធន៍ស្តីពីការលូតលាស់ដំណាំសណ្តែកផ្កាយនៅស្ថានីយ៍ពិសោធន៍កសិកម្មខេត្តតាកែវ

- បន្តសហការជាមួយ Vitrosyste ក្រុមហ៊ុនប្រទេសកូរ៉េ ជំរុញការស្រាវជ្រាវផ្នែកជាលិកាវប្បកម្ម

- បន្តសហការជាមួយ Cambodia-Japan Research Center for Agriculture របស់សាលាជាតិជំរុញការស្រាវជ្រាវលើដំណាំចេកអំបូងពណ៌លឿងរបស់ជប៉ុនក្នុងផ្ទះសំណាញ់នៅសាលាជាតិ

- បន្តសហការជាមួយក្រុមហ៊ុនចិន ពិសោធន៍លើការចិញ្ចឹមត្រីបបែលនៅសាលាជាតិ។

### ១៣.៣ សាលាជាតិកសិកម្មកំពង់ចាម

- និស្សិតដែលកំពុងសិក្សាក្នុងឆ្នាំ២០១៨-២០១៩ សរុបមានចំនួន ៦៥៩នាក់ (ស្រី២៩៦នាក់) លើជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- បានរៀបចំពិសោធន៍ដំណាំលើទឹកដោយប្រើប្រាស់ទឹកអាងចិញ្ចឹមត្រីក្នុងកន្លែងពិសោធន៍ជលផល
- បានរៀបចំពិសោធន៍ជីសរីរាង្គលើការលូតលាស់ដំណាំបន្លែស្ពៃក្រញាញ់
- បានរៀបចំសាកល្បងផលិតមេជី *Lacto bacillus* និងពិសោធឥទ្ធិពលមេជីលើការលូតលាស់ដំណាំស្ពៃក្តោប និងស្រូវនៅស្រុកកំពង់សៀម ខេត្តកំពង់ចាម
- ពិសោធប្រៀបធៀបការបំផ្លាញរបស់កត្តាចង្រៃលើដំណាំខាត់ណាផ្កា
- បានធ្វើការបង្កាត់ពូជកង្កែប និងត្រីទីឡាព្យ៉ាក្រហម
- បន្តការងារមន្ទីរពិសោធន៍ចិញ្ចឹម និងភ្ញាស់ដង្កូវនាងព្រៃ
- បានបន្តផ្តល់ពូជដង្កូវនាងព្រៃឱ្យកសិករចិញ្ចឹមចំនួន ១០គ្រួសារនៅភូមិសំបូរ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម។

## III-សេចក្តីសន្និដ្ឋាន និងវាយតម្លៃ

មកទល់ពេលនេះ ការងារបង្កបង្កើនផលស្រូវរដូវប្រាំងនៅទូទាំងប្រទេសសម្រេចបានចំនួន ៣៣០ ៣៤៩ហ.ត ស្មើនឹង៧១,៨៨% នៃផែនការ ៤៥៩ ៥៩៤ហ.ត។ ក្រសួងក៏បានជំរុញដល់គ្រប់អង្គភាពជំនាញទាំងអស់ ជាពិសេសមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ឱ្យយកចិត្តទុកដាក់គិតគូរទៅលើយន្តការ និងបទដ្ឋានបច្ចេកទេសគន្លឹះសំខាន់ៗតាមការចាំបាច់ និងសហការចុះអន្តរាគមន៍ទាន់ពេលវេលាក្នុងការតាមដានវាយតម្លៃអំពីការប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ ការរាតត្បាតដោយសត្វល្អិតចង្រៃ ការកើតជំងឺផ្សេងៗលើដំណាំកសិកម្ម ជំងឺឆ្លងសត្វ និងការត្រៀមលក្ខណៈនៅពេលកសិករទទួលរងនូវផលប៉ះពាល់ផ្សេងៗជាយថាហេតុ។ ក្រសួងបានសហការជាមួយស្ថាប័នពាក់ព័ន្ធមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត។

អង្គភាពជំនាញនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗតាមការចាំបាច់យ៉ាងយកចិត្តទុកដាក់ ដូចជាការជំរុញឱ្យចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែង ដើម្បីលុបបំបាត់បទល្មើសចលនាសត្វឈើក្នុងតំបន់ផ្ទះជំងឺ បទល្មើសព្រៃឈើ និងជលផលតាមគ្រប់រូបភាព ព្រមទាំងសហការពង្រឹងយន្តការគ្រប់គ្រង ការត្រួតពិនិត្យអនាម័យ និងភូតគាមអនាម័យដោយគិតគូរជាចម្បងទៅលើគុណភាព សុវត្ថិភាព និងសុខុមាលភាពសាធារណៈ។ ជាមួយគ្នានេះ ក្រសួងក៏បានបន្តជំរុញឱ្យគណៈកម្មការ និងក្រុមការងារដែលបានរៀបចំរួចហើយដើម្បីចូលរួមដោះស្រាយលើរាល់បញ្ហាប្រឈមទាំងឡាយដែលកើតឡើងនៅតាមអនុវិស័យនីមួយៗ ព្រមទាំងពង្រឹងស្មារតីទទួលខុសត្រូវក្នុងការឆ្លើយតបឲ្យបានទាន់ពេលវេលាលើមូលបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសារព័ត៌មាននិងបណ្តាញសង្គមផ្សេងៗ។ ទន្ទឹមនឹងនេះ ផ្នែកសេវាកម្ម ដំណើរការនៃកំណែទម្រង់ផ្សេងៗតាមអនុវិស័យសំខាន់ៗ ជាអាទិ៍ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការប្រមូលចំណូលបង់ចូលថវិកាជាតិ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ ការចុះធ្វើអធិការកិច្ចលើការធ្វើអាជីវកម្មសម្ភារកសិកម្ម កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា រួមទាំងការរៀបចំផែនការយុទ្ធសាស្ត្រ គោលនយោបាយតាមអនុវិស័យសំខាន់ៗ និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវ និងសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍ និងទិសដៅដែលត្រូវអនុវត្តក្នុងផែនការអភិវឌ្ឍន៍វិស័យកសិកម្មក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអន្តរស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

ជារួម ដោយមានការជួយឧបត្ថម្ភគាំទ្រគ្រប់បែបយ៉ាងពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍នានា គួបផ្សំនឹងការខិតខំឧស្សាហ៍ព្យាយាម និងការផ្លាស់ប្តូរទម្លាប់របស់ប្រជាកសិករផង បានជំរុញឱ្យដំណើរការផលិតកម្មកសិកម្មទទួលបានជោគជ័យ និងជម្នះដោះស្រាយនូវរាល់ការលំបាកផ្សេងៗប្រកបដោយមោទនភាព ពិតមែនតែនៅមានបញ្ហាប្រឈមខ្លះៗក៏ដោយ។

## IV- ទិសដៅអនុវត្តបន្ត

### ១ ផ្នែកដាំដុះ

- បន្តជំរុញដល់អង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តទាំងអស់ចាត់វិធានការតាមគ្រប់រូបភាពដើម្បីជំរុញការងារបង្កបង្កើនផលស្រូវ និងដំណាំកសិកម្មផ្សេងទៀតតាមរយៈការអនុវត្តបច្ចេកទេស

កសិកម្មសមស្របឱ្យបានទាំងបរិមាណ និងគុណភាពតាមផែនការកំណត់ក្នុងឆ្នាំ២០១៩ ជាពិសេសនៅតំបន់ភូមិសាស្ត្រដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ និងការរក្សាទឹកទុកទៅតាមស្ថានភាពជាក់ស្តែង

- បន្តជំរុញ និងបណ្តុះបណ្តាលមន្ត្រីបច្ចេកទេស និងកសិករអំពីបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម និងបន្តការសិក្សាស្រាវជ្រាវបច្ចេកទេសដាំដុះដំណាំឧស្សាហកម្ម ការងារផលិតពូជ និងបន្សុទ្ធពូជនៅកសិដ្ឋាននិងស្ថានីយ

- ត្រៀមលក្ខណៈមានដូចជាៈ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺ ឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្មសម្រាប់ការងារបង្កបង្កើនផល និងការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលកិច្ចសន្យាផលិតកម្មកសិកម្ម ដើម្បីពិនិត្យអំពីវឌ្ឍនភាព បញ្ហាប្រឈម និងការលើកទិសដៅអនុវត្តបន្ត

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសនៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- បន្តជំរុញឲ្យអង្គភាពជំនាញចុះធ្វើការអប់រំផ្សព្វផ្សាយបច្ចេកទេសដល់កសិករដាំកៅស៊ូឲ្យបានទូលំទូលាយ និងធ្វើការវិភាគសេដ្ឋកិច្ចក៏ដូចជាការបញ្ជ្រាបអំពីតម្លៃកៅស៊ូនៅលើទីផ្សារក្នុងកាលៈទេសៈបច្ចុប្បន្ននេះ។

## ២ ផ្នែកផលិតកម្មនិងបសុព្យាបាល

- បន្តចាត់វិធានការដោយសហការជាមួយក្រសួង ស្ថាប័ន និងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានលើសភាពការណ៍ជំងឺឆ្លងសត្វផ្សេងៗទៀត ព្រមទាំងចាត់ក្រុមការងារចុះអប់រំ ណែនាំ និងជំរុញអង្គភាពជំនាញក្រោមឱវាទរួមទាំងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្ត ដើម្បីត្រៀម និងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង

- បន្តធ្វើការអប់រំណែនាំដល់ប្រជាកសិករឱ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឱ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី-ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- ចុះពិនិត្យអនាម័យសត្តឃាតដ្ឋាន ផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកគ្រុនចៀកខៀវ ប៉េស្ត ជំងឺផ្តាសាយបក្សី ជំងឺអាសន្នរោគ និងវិធានការទប់ស្កាត់នៅតាមរាជធានី-ខេត្ត។

## ៣ ផ្នែករុក្ខាព្រៃឈើ

- បន្តសហការជាមួយរដ្ឋបាលព្រៃឈើមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធដើម្បីចុះស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរសត្វព្រៃ និងបន្តប្រមូលព័ត៌មាន ជំរុញការចុះបញ្ជីកានៃការចិញ្ចឹមសត្វព្រៃជាលក្ខណៈគ្រួសារ សួនសត្វ និងកសិដ្ឋាននៅតាមបណ្តារាជធានី-ខេត្ត

- បន្តចុះតាមដានត្រួតពិនិត្យផ្ទៀងផ្ទាត់លើការងារពាក់ព័ន្ធការកាប់រានដីព្រៃឈើ ចូលរួមសហការការងារជាមួយអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី និងផ្ទៀងផ្ទាត់សំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ កាប់រានដីព្រៃ និងវត្ថុតាងនៃបទល្មើសព្រៃឈើ

- បន្តជំរុញការងារបណ្តុះកូនឈើសម្រាប់ ចែកចាយដល់កសិករដាំអាស្រ័យផល និងចុះសិក្សាទីតាំងដីសម្រាប់បង្កើតជាស្ថានីយ និងចុះបញ្ជីដីស្ថានីយផ្សព្វផ្សាយ និងស្តារព្រៃឈើ

- បន្តការងារស្រាវជ្រាវក្រពើភ្នំ និងបង្រៀនប្រជាសហគមន៍ពីបច្ចេកទេសកសិកម្ម និងការចិញ្ចឹមសត្វ

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ ព្រមទាំងការចាត់វិធានការទប់ស្កាត់ភ្លើងឆេះព្រៃផងដែរ។

## ៤ ផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល ជាពិសេសការយកចិត្តទុកដាក់អនុវត្តឱ្យបានហ្មត់ចត់នូវសេចក្តីសម្រេចលេខ១២៨ សសរ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៦ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសនេសាទនៅបឹងទន្លេសាប

- ជំរុញសង្កាត់ ផ្នែក ខណ្ឌរដ្ឋបាលជលផល និងអធិការដ្ឋានរដ្ឋបាលជលផល បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីជលផលឱ្យបានតឹងរ៉ឹងបំផុត

- បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវ និងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៩ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី កង្កែប បង្គា ក្តាម ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការគ្រប់គ្រងលើការចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោឱ្យបានសមស្របតាមវិធានបច្ចេកទេសនៃការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

## ៥ ផ្នែកពាក់ព័ន្ធផ្សេងៗ

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមរាជធានី-ខេត្ត។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធនឹងការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម ដើម្បីសុខុមាលភាពសាធារណៈ

- បន្តពង្រឹងការងារបញ្ជិកាគណនេយ្យ ការគ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី-ខេត្តក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឱ្យមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរតាមការរំពឹងទុក

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឱ្យបានច្បាស់លាស់សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលសម្រាប់បង់ចូលថវិកាជាតិឱ្យបានសមស្របតាមនីតិវិធី

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទ និងតាមសកម្មភាពជាក់ស្តែង រួមទាំងការរៀបចំវគ្គបណ្តុះបណ្តាលតាមផែនការប្រចាំឆ្នាំដែលបានគ្រោងទុក

- បន្តកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពជំនាញ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន សង្គមស៊ីវិល និងសហគមន៍កសិកម្ម ដើម្បីរិះរកដំណោះស្រាយលើរាល់បញ្ហាប្រឈមនៅតាមអនុវិស័យនីមួយៗលើគ្រប់មធ្យោបាយក្នុងស្មារតីស្ថាបនា ហើយក៏ជាយន្តការមួយរួមចំណែកអភិវឌ្ឍន៍វិស័យកសិកម្មនៅកម្ពុជា ពីកសិកម្មបែបវិបុលវប្បកម្មដែលមានផលិតភាពទាប និងផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯងទៅជាកសិកម្មបែបប្រពលវប្បកម្មមានផលិតភាពខ្ពស់ ការធ្វើកសិកម្មសមស្របដោយគិតគូរជាចម្បងទៅលើការប្រែប្រួលអាកាសធាតុ ស្តង់ដារ ពិសេសការបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម៕

ថ្ងៃ ៣ ៩ កើត ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ៦ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**